# អត្ថប្រយោជន៍
# លើការព្យាបាលជំងឺធ្ងន់ធ្ងរ
# សម្រាប់កុមារ



## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 1 - 17 ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 5 - 21 ឆ្នាំ ( ដល់កាលកំណត់នៅអាយុ22 ) |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $5,000ឡើង |

## អត្ថប្រយោជន៍ធានារ៉ាប់រង

### អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរសម្រាប់កុមារ*

**100%** នៃទឹកប្រាក់ត្រូវបានធានា



*រយៈពេលរស់រានមានជីវិត និងរយៈពេលរង់ចាំត្រូវបានអនុវត្ត!

ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។

# តារាងជំងឺធ្ងន់ធ្ងរ

| | |
|---|---|
|  | ជំងឺមហារីកគ្រាប់ឈាមស |
|  | ជំងឺរលាកស្រោមខួរ<br>បង្កដោយពពួកបាក់តេរី |
|  | ជំងឺរលាកសាច់ខួរក្បាល<br>បង្កដោយពពួកវីរុស |
|  | ជំងឺរលាកសន្លាក់រ៉ាំរ៉ៃដែលបណ្ដាល<br>ឲ្យមានបញ្ហាប្រើសបេះដូង |
|  | ជំងឺដំបៅ ដៃ ជើង និងមាត់<br>ដែលមានផលវិបាកធ្ងន់ធ្ងរ<br>( គំរាមកំហែងដល់អាយុជីវិត ) |
|  | ជំងឺទឹកនោមផ្អែមកើតលើកុមារ<br>ដែលពឹងផ្អែកលើអាំងស៊ុយលីន<br>ក្នុងការព្យាបាល |

# ករណីមិនធានា

ក្រុមហ៊ុនមិនផ្តល់សំណងទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលដែលបណ្តាលមកពីព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

១. ជំងឺផ្សេងទៀតក្រៅពីជំងឺធ្ងន់ធ្ងររបស់កុមារ ដូចមានកំណត់នៅក្នុងផលិតផលនេះ។
២. ជំងឺអេដស៍ ឬជំងឺបណ្តាលមកពីជំងឺអេដស៍ ឬជំងឺពាក់ព័ន្ធនឹងវីរុសហ៊ីវ។
៣.ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

(១) អ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល
(២) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ
(៣) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ
(៤) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

៤. ជំងឺធ្ងន់ធ្ងររបស់កុមារកើតមាន ឬត្រូវបានធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំ។
៥. អ្នកត្រូវបានធានារ៉ាប់រងមិនមានជីវិតរស់នៅក្នុងរយៈពេលរស់រានមានជីវិត បន្ទាប់ពីធ្វើរោគវិនិច្ឆ័យរកឃើញជំងឺធ្ងន់ធ្ងររបស់កុមារណាមួយ។
៦. ជំងឺកើតចេញពីការសាយភាយដោយផ្ទាល់ ឬដោយប្រយោលនូវធាតុវិទ្យុសកម្មពីថាមពលនុយក្លេអ៊ែរ ឬសំណល់នុយក្លេអ៊ែរ ដែលបង្កឡើងដោយដំណើរការបំលែងថាមពលនុយក្លេអ៊ែរ ឬអាវុធនុយក្លេអ៊ែរ។
៧. ភាពមិនប្រក្រតីនៃសរីរាង្គពីកំណើត ឬជំងឺតំណពូជ។
៨. អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណចុះបញ្ជីត្រឹមត្រូវ។